**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ: ធ៦១-០៤៥-១១០៧.ស.ស.ហ

*ថ្ងៃពុធ ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥*

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២៣៤

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២៣៤ ដែលមានឥណប្រតិទាន ៧ថ្ងៃ ៩១ថ្ងៃ និង១៨២ថ្ងៃ នឹងត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃព្រហស្បតិ៍ ទី២១ ខែសីហា ឆ្នាំ២០២៥។ ចំពោះការទូទាត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២៣៤ គ្រប់ឥណប្រតិទាននឹងត្រូវធ្វើឡើងនៅក្នុងថ្ងៃដដែល ។ ព័ត៌មានពាក់ព័ន្ធនឹងការដេញថ្លៃនេះ មានដូចតទៅ៖

| | |
|---|---|
| -ពេលវេលាដាក់ដេញថ្លៃ | :ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ០៩:០០ ព្រឹក |
| -នីតិវិធីដេញថ្លៃ | :ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល)<br>និងអត្រាការប្រាក់ដាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស) |
| -វត្ថុធានា | :- NCD ឬ មូលបត្ររដ្ឋ ជាវត្ថុធានាត្រូវមានឥណប្រតិទានវែងជាង ឬស្មើនឹងឥណប្រតិទានរបស់ LPCO<br>- គ្រឹះស្ថានអាចប្រើប្រាស់សមតុល្យក្នុងគណនីចរន្តជាវត្ថុធានាបាន |
| -ហ៊ែខាត់លើវត្ថុធានាជាដុល្លារអាមេរិក | :៣% |
| -ទំហំទឹកប្រាក់ដេញថ្លៃអប្បបរមា | :២០០.០០០.០០០ (ពីររយលាន) រៀល |
| -ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា | :មិនកំណត់ |

ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ អត្រាការប្រាក់ និងថ្ងៃឥណប្រតិទាន មានដូចតទៅ៖

| ប្រភេទ LPCO | ថ្ងៃឥណប្រតិទាន | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | អត្រាការប្រាក់ដាក់ដេញថ្លៃអប្បបរមា |
|---|---|---|---|
| ៧ថ្ងៃ(D07) | ២៨ សីហា ២០២៥ | ២៥០.០០០.០០០.០០០ រៀល | ២,៧៥% |
| ៩១ថ្ងៃ (D91) | ២០ វិច្ឆិកា ២០២៥ | ១០០.០០០.០០០.០០០ រៀល | ៣,២៥% |
| ១៨២ថ្ងៃ (D182) | ១៩ កុម្ភៈ ២០២៦ | ២៥.០០០.០០០.០០០ រៀល | ៣,៥០% |



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការដេញថ្លៃនឹងធ្វើតាមរយៈថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) តាមកាលវិភាគដែលបានកំណត់។ ក្នុងករណី NBCP មិនអាចអនុវត្តបាន គ្រឹះស្ថានត្រូវបញ្ជូនពាក្យសុំដេញថ្លៃតាមសារអេឡិចត្រូនិក marketoperations@nbc.gov.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត និងផ្ញើមកនាយកដ្ឋានទីផ្សាររូបិយវត្ថុ ឱ្យបានមុនម៉ោង ០៩:០០ ព្រឹក នៅថ្ងៃដេញថ្លៃ។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសក្រោយបញ្ចប់ការដេញថ្លៃ នាថ្ងៃដដែល។ គ្រឹះស្ថានដែលដេញថ្លៃឈ្នះត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មាធិការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។


**សូមទំនាក់ទំនង ៖ នាយកដ្ឋានទីផ្សាររូបិយវត្ថុ**

លេខទូរស័ព្ទ : (៨៥៥-២៣) ៩៩០ ១៩០

សារអេឡិចត្រូនិក : markets.info@nbc.gov.kh


**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**

www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA